កិច្ចការ២០:៥-៣៨

## កិច្ចការសាវ័កប៉ុលនៅក្រុងទ្រអាស

ទីក្រុងទ្រអាសជាទីក្រុង ដែលសាវ័កប៉ុលត្រៀមលក្ខណៈទាំងចិត្ត ទាំងកាយវិញ្ញាណ ដើម្បីនាំដំណឹងល្អចូលទៅក្នុងទ្វីបអឺរ៉ុប។ លោកចាកចេញពីនៅទីនោះ ពេលលោកបញ្ចប់ដំណើរបេសកកម្មលើកទីពីរ។ ឥឡូវ លោកអញ្ជើញត្រឡប់មកដល់ទីក្រុងទ្រអាសម្តងទៀត ក្នុងដំណើរបេសកកម្មចុងក្រោយរបស់លោក។

### អ្នកទាំងនោះចេញទៅមុន ក៏ចាំយើងរាល់គ្នានៅត្រង់ក្រុងទ្រអាស (កិច្ចការ២០:៥)។

ពាក្យថា "យើង" បណ្ឌិតលូកាដែលជាអ្នកកត់ត្រាគម្ពីរកិច្ចការបញ្ជាក់ និងសាវ័កប៉ុលនៅរង់ចាំងទីក្រុងទ្រអាស ក្នុងពេលដែលគូកនរបស់លោកជាច្រើននាក់បានទៅផ្សាយដំណឹងល្អនៅទីកន្លែងដទៃៗទៀត។ នៅក្នុងក្រុមរបស់សាវ័កប៉ុល មានមនុស្សឧស្សាហ៍ច្រើនណាស់ដើរផ្សព្វផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ពេលណាសាវ័កប៉ុលទៅដល់ទីក្រុងណាមួយ លោកជាប់ដៃបម្រើកិច្ចការងាររបស់ព្រះអង្គនៅក្នុងទីក្រុងនោះ។ គូកនរបស់លោកធ្វើដំណើរទៅភូមិ ឃុំ ស្រុកនានា ដែលនៅជុំវិញ

ទីក្រុងនោះ។ ករណីនេះ កើតឡើងនៅទីក្រុងកូរិនថូសដែរ។ នៅក្នុងគម្ពីរកូល៉ុសយើងឃើញថា ព្រះបន្ទូលរបស់ព្រះ បានរីកសាយទៅដល់ទីកន្លែងដែលពួកសាវ័កមិនទាន់ទៅដល់ផង។ នៅក្នុងសម័យនោះ រាជការរ៉ូមជាអ្នកគ្រប់គ្រងសកលលោកទាំងមូល។ ដូច្នេះ ទីណាដែលមានរាជការរ៉ូមគ្រប់គ្រង ទីនោះដំណឹងល្អបានទៅដល់យ៉ាងសុសសាយ។ គម្ពីរកិច្ចការគ្រាន់តែសម្ដែងអំពីកិច្ចការរបស់សាវ័កពេត្រុស និងសាវ័កប៉ុលតែប៉ុណ្ណោះទេ។ ចំណែកសាវ័កដទៃៗទៀត ព្រមទាំងអស់អ្នកជឿដល់ព្រះអង្គតាមរយៈពួកសាវ័កទាំងនោះ នាំគ្នាដើរគ្រប់ទីកន្លែង ដើម្បីផ្សព្វផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សាវ័កពេត្រុសផ្សព្វផ្សាយដំណឹងល្អជាមួយនឹងសាសន៍យូដា រីឯសាវ័កប៉ុលវិញ ផ្សព្វផ្សាយដំណឹងល្អជាមួយនឹងសាសន៍ដទៃ។

**ក្រោយថ្ងៃបុណ្យនំបុ័ងឥតដំបែ នោះយើងក៏ចុះសំពៅ ចេញពីក្រុងភីលីពទៅ៥ថ្ងៃ ទើបបានដល់ទៅគេនៅទ្រអាស រួចយើងស្នាក់នៅទីនោះអស់៧ថ្ងៃ (កិច្ចការ២០:៦)។**

ការធ្វើដំណើររបស់សាវ័កប៉ុល ត្រូវចំណាយពេលអស់ប្រាំថ្ងៃ ទើបទៅដល់គោលដៅ។ បច្ចុប្បន្ននេះ ពួកដែលគេធ្វើទេសចរណ៍ ចំណាយពេលតែហាសិបនាទីប៉ុណ្ណោះទេ។ ការធ្វើដំណើរសព្វថ្ងៃលឿនជាងសម័យដើមឆ្ងាយណាស់។ ប៉ុន្តែ ទោះជាការធ្វើដំណើរសព្វថ្ងៃលឿនជាងសម័យដើមរាប់រយដង សកម្មភាពផ្សាយដំណឹងល្អ

របស់ព្រះអម្ចាស់យេស៊ូវ មិនបានលឿនដូចមធ្យោបាយធ្វើដំណើរសព្វថ្ងៃនេះឡើយ។

**លុះថ្ងៃដំបូងក្នុងអាទិត្យនោះ កាលពួកសិស្សបានប្រជុំគ្នា ដើម្បីកាច់នំបុ័ង នោះប៉ុលក៏អធិប្បាយឱ្យគេស្តាប់ ដោយព្រោះគាត់រៀបនឹងចេញដំណើរទៅ នៅថ្ងៃស្អែក ក៏សំដែងដរាបដល់ពេលកណ្តាលអធ្រាត្រ (កិច្ចការ២០:៧)។**

នៅក្នុងខខាងលើមានហេតុការណ៍ខ្លះៗ ដែលយើងចាំបាច់ត្រូវយកមកពន្យល់អោយបានច្បាស់លាស់។ ចំណុចទីមួយ គឺគេនាំគ្នាជួបជុំគ្នា ដើម្បីថ្វាយបង្គំព្រះនៅថ្ងៃទីមួយ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ពួកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ សម្រេចយកថ្ងៃទីមួយក្នុងសប្តាហ៍ ដើម្បីថ្វាយបង្គំដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ នៅក្នុងគម្ពីរកូរិនថូស សាវ័កប៉ុលសរសេរសំបុត្រទៅរំឭកពួកជំនុំនៅទីក្រុងនោះថា ត្រូវនាំដង្វាយមកថ្វាយដល់ព្រះអង្គនៅថ្ងៃទីមួយ (សូមអាន១កូរិនថូស១៦:២)។ នៅក្នុងខដែលយើងកំពុងសិក្សានេះ មានសេចក្តីដែលចែងថា "លុះថ្ងៃដំបូងក្នុងអាទិត្យនោះ កាលពួកសិស្សបានប្រជុំគ្នា ដើម្បីកាច់នំបុ័ង..."។ ត្រង់នេះមានន័យថា ពិធីលៀងព្រះអម្ចាស់ ឬពិធីរួមសម្ពន្ធវង្សបរិសុទ្ធត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃអាទិត្យ ដែលជាថ្ងៃទីមួយនៅក្នុងសប្តាហ៍។ នៅថ្ងៃទីមួយ សាវ័កប៉ុលតែងតែអធិប្បាយព្រះបន្ទូលរបស់ព្រះអង្គនៅតាមពួកជំនុំ ពីព្រោះជាថ្ងៃដែលគេថ្វាយបង្គំដល់ព្រះជាម្ចាស់។ ថ្ងៃទីមួយ មានសារៈសំខាន់

ណាស់ សម្រាប់គ្រីស្ទបរិស័ទ ពីព្រោះជាថ្ងៃដែលព្រះអម្ចាស់យេស៊ូវរស់ពីសុគត ឡើងវិញ។ ថ្ងៃទីប្រាំពីរ គឺជាថ្ងៃដែលរួមសំបាច់ជាមួយនឹងមាបនកម្មចាស់។ ថ្ងៃសៅរ៍ គឺជាថ្ងៃឈប់សម្រាក។ នៅថ្ងៃឈប់សម្រាក ព្រះយេស៊ូវសុគតនៅក្នុងផ្នូរនៅឡើយ។ លុះដល់ថ្ងៃទីមួយដើមសប្តាហ៍ ព្រះយេស៊ូវរស់ពីសុគតឡើងវិញ។ គ្រីស្ទបរិស័ទនាំគ្នា កំណត់ថ្ងៃដំបូងបង្អស់ក្នុងសប្តាហ៍ ដើម្បីរួមសម្ព័ន្ធវង្សជាមួយនឹងព្រះអម្ចាស់យេស៊ូវ ដែលទ្រង់រស់ពីសុគតឡើងវិញ។ ការជួបជុំគ្នាថ្វាយបង្គំដល់ព្រះអង្គនៅថ្ងៃទីមួយ គឺជាទី បន្ទាល់ប្រាប់ដល់មនុស្សលោកថា ព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញនៅថ្ងៃទីមួយ។

សេចក្តីទីពីរដែលសំខាន់ដែរនៅក្នុងខនេះដែរ គឺសាវ័កប៉ុលត្រូវចាកចេញ ដំណើរនៅថ្ងៃស្អែក។ ដូច្នេះ យប់នេះគាត់អធិប្បាយរហូតដល់ពាក់កណ្តាលអធ្រាត្រ។ ខ្ញុំសន្យាថា បើខ្ញុំអធិប្បាយដល់ពាក់កណ្តាលអធ្រាត្រវិញ ជាគ្មានមនុស្សណាម្នាក់ស្តាប់ខ្ញុំ ឡើយ។ ម្យ៉ាងទៀត មិនមែនតែខ្ញុំប៉ុណ្ណោះទេ ទោះបីគ្រូអធិប្បាយណាក៏ដោយ បើ អធិប្បាយរហូតដល់ពាក់កណ្តាលអធ្រាត្រក្នុងពេលសព្វថ្ងៃនេះ ក៏គ្មានមនុស្សណាស្តាប់ ដែរ។ ប៉ុន្តែ សូមអោយយើងយល់អំពីស្ថានភាពជាក់ស្តែងដែលសាវ័កប៉ុលចាំបាច់ត្រូវ អធិប្បាយរហូតដល់ពាក់កណ្តាលអធ្រាត្រ។ លោកមិនអាចអញ្ជើញត្រឡប់មកទីក្រុង នេះម្តងទៀតទេ។ លោកចេញដំណើរលើកនេះ លោកមិនអាចអញ្ជើញត្រឡប់មកជួប ពួកជំនុំនៅទីក្រុងនេះបានទៀតឡើយ។ ហេតុដូច្នេះហើយបានជាលោកអធិប្បាយយ៉ាង វែងជាទីបំផុត។

ខ្ញុំផ្ទាល់ចូលចិត្តអធិប្បាយវែងដែរ។ ខ្ញុំចេះបកស្រាយគម្ពីរដោយសិក្សាខ្លួនឯង គួបផ្សំជាមួយនឹងចំណេះវិជ្ជាខ្លះៗ ដែលខ្ញុំរៀននៅសាលាព្រះគម្ពីរ។ បើខ្ញុំចង់ពង្រីកសេចក្តីអធិប្បាយណាមួយអោយវែង ខ្ញុំអាចធ្វើអោយវែងបាន។ លោកអ្នកបងប្អូនប្រហែលជាសួរមកខ្ញុំថា ហេតុអ្វីក៏លោកគ្រូចេះអធិប្បាយវែងៗពីណាមក? ខ្ញុំឆ្លើយថា ខ្ញុំរៀនពីសាវ័កប៉ុល។ បើខ្ញុំអធិប្បាយវែងដល់ពាក់កណ្តាលអធ្រាត្រ លោកអ្នកបងប្អូនកុំបន្ទោសខ្ញុំ។

**រីឯនៅបន្ទប់ខាងលើ ជាកន្លែងដែលគេប្រជុំ នោះមានចង្កៀងជាច្រើន (កិច្ចការ២០:៨)។**

នៅក្នុងកន្លែងប្រជុំគេដុតភ្លើងបំភ្លឺយ៉ាងចិញ្ចែង។ គ្រីស្ទបរិស័ទនៅនាំគ្នាអង្គុយរហូតដល់ពាក់កណ្តាលអធ្រាត្រ មិនមែនអង្គុយស៊ីផឹក ឬលេងល្បែងស៊ីសងទេ។ គ្រីស្ទបរិស័ទទាំងនោះ អង្គុយរហូតដល់ពាក់កណ្តាលអធ្រាត្រ ពីព្រោះគេចង់ស្តាប់ព្រះបន្ទូលព្រះអង្គ ព្រមទាំងលើកសរសើរដំកើងដល់នាមទ្រង់។ សព្វថ្ងៃនេះ គ្រីស្ទបរិស័ទបណ្តោយអោយលោកីយ៍ឆក់យកសេចក្តីរីករាយសប្បាយអស់រលីងពីក្រុមជំនុំ។ កាលណាពួកជំនុំជួបជុំគ្នា ច្រើនតែធ្វើមុខជូរ ដូចជាមានទម្ងន់មហាទុក្ខគ្របសង្កត់លើខ្លួនយ៉ាងដូច្នោះ។ យើងជាគ្រីស្ទបរិស័ទអាចបង្កើតអោយមានការសប្បាយរីករាយអបអរសាទរដែរ បើយើងចេះធ្វើអោយមានការសប្បាយ ដែលមានលក្ខណៈបរិសុទ្ធ។ សាវ័ក

ប៉ុលអធិប្បាយរហូតដល់ពាក់កណ្ដាលអធ្រាត្រ ពីព្រោះមានពួកជំនុំដែលប្រុងស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គមានការសប្បាយរីករាយ។ ប៉ុន្តែ កំពុងតែលោកអធិប្បាយមានហេតុការណ៍មួយកើតឡើង។

> **គ្រានោះ មានក្មេងជំទង់ម្នាក់ ឈ្មោះអើទីកុសវាអង្គុយនៅបង្អួច ក៏យន់ជាខ្លាំងពេក ក្នុងពេលដែលប៉ុលអធិប្បាយជាយូរទៅ ទៀត រួចងោកធ្លាក់ចុះពីជាន់ទី៣ទៅខាងក្រោម នោះគេលើកវាឡើងបានស្លាប់ហើយ (កិច្ចការ២០:៩)។**

មានគ្រូអធិប្បាយមួយរូបនិយាយថា គាត់ពូកែអធិប្បាយជាងសាវ័កប៉ុលទៅទៀត។ នៅវិហារស្រុកស្រែ ពេលអធិប្បាយកូនក្មេងតែងនៅជាមួយចាស់ៗ។ ឯកូនង៉ែតដែលនៅបៅដោះម្ដាយនៅឡើយ ម្ដាយតែងតែពរ ហើយអោយនៅជាមួយនឹងម្ដាយ។ គ្រូអធិប្បាយនោះអធិប្បាយយូរៗទៅ មានកូនក្មេងបួននាក់ដេកលក់ស៊ប់។ គាត់និយាយថា "សាវ័កប៉ុលអធិប្បាយមានក្មេងតែម្នាក់ដែលដេកលក់ តែខ្ញុំវិញ អធិប្បាយមានកូនក្មេងដល់ទៅបួននាក់ដេកលក់ស៊ប់"។

ខ្ញុំទទួលការលើកទឹកចិត្តយ៉ាងខ្លាំង ដោយសារឃើញមានមនុស្សដេកលក់ពេលសាវ័កប៉ុលអធិប្បាយ។ ពេលខ្លះខ្ញុំអធិប្បាយនៅក្នុងព្រះវិហារ ខ្ញុំឃើញមានពួកជំនុំពីរបីនាក់ងងុយដេក ភ្នែកមមីរ។ អ្នកជឿព្រះអង្គខ្លះក៏ដេកលក់ រួចហើយលក់ស្រមុក

ផង។ ខ្ញុំតែងតែគិតក្នុងចិត្តថា ហេតុអ្វីបានជាសេចក្តីអធិប្បាយរបស់ខ្ញុំធ្វើអោយគេដេកលក់យ៉ាងដូច្នេះ? លុះដល់ឃើញថាសាវ័កប៉ុលអធិប្បាយក៏មានមនុស្សដេកដែរ ខ្ញុំមានចិត្តធូរស្រាលបន្តិច។

ក្មេងជំទង់ម្នាក់ឈ្មោះអើទីកុស ដេកលក់កំពុងតែសាវ័កប៉ុលអធិប្បាយ។ ខ្ញុំមិនដឹងថា គាត់ស្រម៉ុកដែរ ឬមួយយ៉ាងណានោះទេ។ ក្មេងម្នាក់នេះ ធ្លាក់ពីលើជាន់ទីបី។ បើយើងចង់សើចដោយអ្នកនោះងោកធ្លាក់ពីលើជាន់ទីបី ក៏សើចមិនចេញ ពីព្រោះយើងមិនអាចសើចកើតទេ។ បើសិនជាក្មេងនេះស្លាប់រហូត ការប្រជុំនោះរាប់ថាជាការមិនគួរគប្បីឡើយ។ ប៉ុន្តែ រឿងនោះមិនយ៉ាងដូច្នេះទេ។

**១០ តែប៉ុលចុះទៅទ្រោបពីលើវាឱបត្រកង រួចនិយាយថា កុំយំ**
**ស្រែកអ្វីឡើយ ដ្បិតវាមានជីវិតទេ ១១ កាលបានឡើងទៅលើវិញ**
**ហើយបានកាច់នំបុ័ងបរិភោគទៅ នោះក៏និយាយគ្នាជាយូរទៅ**
**ទៀត ដរាបដល់ភ្លឺ ទើបគាត់ចេញដំណើរទៅ ១២ គេក៏នាំក្មេង**
**ជំទង់នោះមកវិញទាំងរស់ ហើយគេបានក្សាន្តចិត្តជាខ្លាំង (កិច្ចការ២០:១០-១២)។**

សាវ័កប៉ុលចុះទៅប្រោសអោយខ្មោចក្មេងជំទង់នេះ មានជីវិតឡើងវិញ។ សាវ័កពេត្រុស ក៏អាចប្រោសមនុស្សម្នាក់ស្លាប់អោយមានជីវិតឡើងវិញដែរ។ នាងនោះ

ឈ្មោះនាងក្តាន់។ លោកទាំងពីរសុទ្ធតែមានអំណោយទាន បញ្ជាក់ថា លោកជាពួកសាវ័ក។ ប៉ុន្តែ បន្ទាប់ពីព្រះគម្ពីរសរសេរជាលាយល័ក្ខណ៍អក្សរបានពេញលេញ ទីសម្គាល់ដែលបញ្ជាក់ថា មនុស្សណាម្នាក់ជាសាវ័កបានបាត់ពីក្នុងក្រុមជំនុំទៅ។ បណ្ឌិតលូកាបញ្ជាក់អំពីបទពិសោធនេះថា "គេបានក្សាន្តចិត្តជាខ្លាំង"។ ត្រង់នេះមានន័យថាពួកអ្នកអង្គុយស្តាប់សេចក្តីអធិប្បាយរបស់សាវ័កប៉ុល មានចិត្តរីករាយយ៉ាងខ្លាំងដោយឃើញថា ក្មេងដែលស្លាប់ទៅនោះ ឥឡូវនេះ មានជីវិតឡើងវិញហើយ។ បន្ទាប់ពីហេតុការណ៍នោះកើតឡើង សាវ័កប៉ុលបន្តសេចក្តីអធិប្បាយរបស់លោករហូតដល់ភ្លឺ។ បទពិសោធន៍របស់សាវ័កប៉ុល នៅក្នុងអត្ថបទគម្ពីរកិច្ចការជំពូក២០ ជាការបន្ទោសដល់យើងទាំងអស់គ្នាជាពួកជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សព្វថ្ងៃពួកជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ភាគច្រើនតែងតែរអ៊ូរទាំ ពេលណាគ្រូគង្វាលអធិប្បាយលើសដប់ឬម្ភៃនាទី ពិសេសបើគ្រូអធិប្បាយនោះគាត់កំពុងអធិប្បាយចំសេចក្តីដែលត្រូវនិយាយ។ អ្នកជឿសម័យដើម អង្គុយស្តាប់សាវ័កប៉ុលអធិប្បាយរហូតទល់ភ្លឺ។ អ្នកខ្លះនិយាយថា បើសាវ័កប៉ុលមកអធិប្បាយនៅពេលសព្វថ្ងៃនេះ យើងស្តាប់លោកទល់ភ្លឺ ដូចជាក្រុមជំនុំសម័យដើមដែរ។ ប៉ុន្តែសាវ័កប៉ុល មិនមែនជាអ្នកដែលពូកែអធិប្បាយជាងគ្រូអធិប្បាយខ្លះសព្វថ្ងៃ ដែលពូកែនោះទេ។ នៅក្នុងគម្ពីរយើងមិនឃើញថា មានកន្លែងណាដែលនិយាយបញ្ជាក់សាវ័កប៉ុលថាជាអ្នកអធិប្បាយពូកែដែរ។ ចំណែកលោកអ័ប៉ុឡូសទើបគម្ពីរចែងថា គាត់ជាអ្នកមានវោហារ។ ពួកជំនុំសម័យដើម ចង់ស្តាប់ព្រះបន្ទូលខ្លាំងណាស់។ ខ្ញុំចង់ឃើញពួកជំនុំសព្វថ្ងៃនេះ ចូលចិត្តស្តាប់ព្រះបន្ទូលរបស់ព្រះ ដូចក្រុម

ជំនុំសម័យដើមដែរ។

## កិច្ចការសាវ័កប៉ុលនៅក្រុងមីលេត

**ឯយើងរាល់គ្នា ក៏ចុះសំពៅជាមុន បើកទៅដល់អាសុស ចាំទទួលប៉ុលនៅទីនោះ ដ្បិតគាត់បានផ្តាំផ្ញើដូច្នោះ ព្រោះគាត់ចង់ដើរវិញ (កិច្ចការ២០:១៣)។**

ពេលនេះ ក្រុមរបស់សាវ័កប៉ុលធ្វើដំណើរទៅមុខទៀតហើយ។ បណ្ឌិតលូកា ព្រមទាំងពួកគូកនដទៃៗទៀត នាំគ្នាចុះសំពៅឆ្ពោះទៅទីក្រុងអាសុស តែសាវ័កប៉ុលធ្វើដំណើរដោយថ្មើរជើងវិញ។ លោកចាំបាច់ត្រូវធ្វើដំណើរថ្មើរជើង ពីព្រោះលោកចង់ផ្សព្វផ្សាយដំណឹងល្អតាមផ្លូវ ដែលលោកធ្វើដំណើរចុះទៅទីនោះ។ សាវ័កប៉ុលឧស្សាហ៍ផ្សព្វផ្សាយដំណឹងល្អណាស់។

**១៤កាលគាត់មកដល់យើងនៅក្រុងអាសុស នោះយើងទទួលគាត់ចុះសំពៅទៅឯមីទូលេន ១៥ក៏ចេញពីទីនោះ រួចស្អែកឡើងបាននៅដល់ទន្ទឹមនឹងកោះឃីយ៉ូស ហើយដល់ថ្ងៃក្រោយទៀត យើង**

**បានដល់ទៅសាម៉ុស រួចចូលចតនៅក្រុងទ្រូគីលាម លុះថ្ងៃក្រោយទៀត ទើបបានដល់ទៅក្រុងមីលេត (កិច្ចការ២០:១៤-១៥)។**

ទីក្រុងខាងលើទាំងអម្បាលមាណនេះ ពិបាកហៅណាស់ ប៉ុន្តែទោះពិបាកយ៉ាងដូច្នោះក៏ដោយ យើងរៀនខ្លះៗអំពីភូមិសាស្ត្ររបស់កន្លែងសាវ័កប៉ុលបានធ្វើដំណើរទៅផ្សព្វផ្សាយដំណឹងល្អ។

**ដ្បិតប៉ុលបានសំរេចនឹងទៅបង្ហួសក្រុងអេភេសូរ ដើម្បីមិនឲ្យខាតពេលនៅស្រុកអាស៊ី ដោយគាត់ប្រញាប់នឹងទៅឯក្រុងយេរូសាឡិម ឲ្យទាន់ពេលបុណ្យថ្ងៃ៥០ បើសិនជាបាន (កិច្ចការ២០:១៦)។**

វត្ថុបំណងរបស់សាវ័កប៉ុល គឺចង់ធ្វើដំណើរទៅអោយទាន់ថ្ងៃបុណ្យថ្ងៃទីហាសិប ដែលប្រព្រឹត្តទៅនៅទីក្រុងយេរូសាឡិម។ ដូច្នេះ លោកត្រូវធ្វើដំណើរអោយបានរួសរាន់អោយទាន់ថ្ងៃដែលគេធ្វើបុណ្យនោះ។ ប៉ុន្តែ ទោះបីជាយ៉ាងនោះក៏ដោយ លោកមិនចង់ខានជួបជាមួយនឹងពួកជំនុំនៅទីក្រុងអេភេសូរទេ។ លោកឈប់នៅទីក្រុងមីលេត ដែលជាកំពង់ផែចូលទៅក្រុងអេភេសូរ។

**ប៉ុលក៏ចាត់គេ ពីមីលេតទៅឯក្រុងអេភេសូរ ដើម្បីនឹងហៅពួកចាស់ទុំក្នុងពួកជំនុំនោះមក (កិច្ចការ២០:១៧)។**

ទីក្រុងអេភេសូរជាទីក្រុងដែលចូលជ្រៅទៅក្នុងដីគោក។ ទីក្រុងនេះ ស្ថិតនៅប្រមាណបួនគីឡូម៉ែត្រពីមាត់សមុទ្រ។ ទីក្រុងអេភេសូរមានដៃសមុទ្របីចូលទៅជួបគ្នានៅទីនោះ។ ទីក្រុងមីលេតវិញ ជាកំពង់ផែនៅឯមាត់សមុទ្រឯណោះទេ។ នៅពេលដែលសាវ័កប៉ុលធ្វើដំណើរទៅដល់ទីក្រុងមីលេត លោកបញ្ជូនអោយមនុស្សទៅហៅពួកចាស់ទុំនៅទីក្រុងអេភេសូរ ដើម្បីមកជួបលោកនៅទីនេះ។

**១៨ លុះមកដល់ហើយ គាត់និយាយទៅគេថា ឯកិរិយារបស់ខ្ញុំ គ្រប់
ពេល គ្រប់វេលា ដែលនៅជាមួយនឹងអ្នករាល់គ្នា តាំងពីថ្ងៃដែល
ខ្ញុំចូលទៅស្រុកអាស៊ីមុនដំបូង ១៩ គឺដែលខ្ញុំបានបំរើព្រះអម្ចាស់
ដោយចិត្តសុភាពគ្រប់ជំពូក ហើយស្រក់ទឹកភ្នែកជាច្រើន ទាំងត្រូវ
សេចក្តីល្បួង ដោយកិច្ចកលរបស់ពួកសាសន៍យូដាបែបយ៉ាងណា
នោះអ្នករាល់គ្នាដឹងស្រាប់ហើយ ២០ ក៏ដឹងថា ខ្ញុំមិនបានខាននឹង
ប្រាប់សេចក្តីអ្វីដែលមានប្រយោជន៍ដល់អ្នករាល់គ្នាដែរ គឺបាន
បង្រៀនដល់អ្នករាល់គ្នានៅកណ្តាលជំនុំវិញ ហើយពីផ្ទះ១ទៅ
ផ្ទះ១ផង ២១ ក៏ធ្វើបន្ទាល់អស់ពីចិត្ត ដល់ទាំងពួកសាសន៍យូដានឹង**

**ពួកសាសន៍ក្រេកផង គឺពីការប្រែចិត្តទៅឯព្រះហើយពីសេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងរាល់គ្នា (កិច្ចការ ២០:១៨-២១)។**

សាវ័កប៉ុលជាអ្នកស្មោះត្រង់ ក្នុងការធ្វើបន្ទាល់ពីអង្គព្រះយេស៊ូវគ្រីស្ទ។ លោកមិនចង់អោយខាតពេលវេលា សូម្បីតែបន្តិចសោះឡើយ។ លោកមានបំណងតែម្យ៉ាង គឺលោកចង់បង្ហាត់បង្រៀនដល់ពួកបណ្តាជនអោយស្គាល់ព្រះបន្ទូលរបស់ព្រះ ព្រមទាំងអនុវត្តតាមព្រះបន្ទូលរបស់ព្រះអង្គផង។ សាវ័កប៉ុលបង្ហាត់បង្រៀនគោលទិ្ធនៃព្រះគម្ពីរទាំងមូល ចាប់តាំងពីគ្រាដែលព្រះអង្គបង្កបង្កើតផ្ទៃមេឃនិងផែនដី រហូតដល់ថ្ងៃដែលព្រះអម្ចាស់ទ្រង់យាងមកប្រមូលរាស្ត្ររបស់ទ្រង់អោយទៅនៅជាមួយនឹងព្រះអង្គនៅឯនគរស្ថានសួគ៌។ ដូច្នេះ គំនិតដែលបង្ហាត់បង្រៀនព្រះគម្ពីរទាំងមូលតែម្តងនោះ មិនមែនមានតែខ្ញុំតែប៉ុណ្ណោះទេ រឿងនេះគេធ្វើតាំងពីដើមកន្លងមក។ សាវ័កប៉ុលបង្ហាត់បង្រៀនក្រឹត្យវិន័យទាំងអស់របស់ព្រះដល់មនុស្សលោក។ លោកមានសេចក្តីស្មោះត្រង់នឹងកាតព្វកិច្ចនេះណាស់ ទោះបីអ្នកដឹកនាំសាសនា និងអ្នកនយោបាយសាសន៍យូដាប្រឆាំងនឹងលោកយ៉ាងណាក៏ដោយ។

**២២ ឥឡូវនេះ មើល ខ្ញុំមានសេចក្តីបណ្តាលក្នុងចិត្ត ចង់ទៅឯក្រុងយេរូសាឡិម ឥតដឹងការអ្វី ដែលនឹងកើតដល់ខ្ញុំនៅទីនោះទេ**

**២៣ដឹងតែប៉ុណ្ណេះថា ព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់ដល់ខ្ញុំ នៅគ្រប់
ទីក្រុងថា មានចំណង នឹងសេចក្តីវេទនា នៅរង់ចាំខ្ញុំ ២៤ប៉ុន្តែ
នោះមិនអំពល់អ្វីដល់ខ្ញុំទេ ខ្ញុំក៏មិនរាប់ជីវិតនេះ ទុកជារបស់
វិសេសដល់ខ្ញុំដែរ ឲ្យតែខ្ញុំបានបង្ហើយការរត់ប្រណាំងរបស់ខ្ញុំ
ដោយអំណរចុះ ព្រមទាំងការងារ ដែលខ្ញុំបានទទួលអំពីព្រះ
អម្ចាស់យេស៊ូវ គឺឲ្យខ្ញុំបានធ្វើបន្ទាល់សព្វគ្រប់ ពីដំណឹងល្អនៃព្រះ
គុណព្រះវិញ (កិច្ចការ២០:២២-២៤)។**

ចំណុចខាងលើ គឺជាចំណុចដែលគ្រូអធិប្បាយមិនយល់ស្របជាមួយគ្នាទាំងស្រុងទេ។ គ្រូខ្លះយល់ថា ការធ្វើដំណើរចុះទៅទីក្រុងយេរូសាឡិម ជាការសម្រេចចិត្តខុសយ៉ាងធំរបស់សាវ័កប៉ុល។ ប៉ុន្តែ ខ្ញុំយល់ថា ការធ្វើដំណើរទៅទីក្រុងយេរូសាឡិម សាវ័កប៉ុលដឹងពីព្រះហឫទ័យបំណងរបស់ព្រះច្បាស់លាស់ណាស់។ លោកបញ្ជាក់ក្នុងខនេះថា "...ខ្ញុំមានសេចក្តីបណ្តាលក្នុងចិត្ត ចង់ទៅឯក្រុងយេរូសាឡិម ឥតដឹងការអ្វីដែលនឹងកើតដល់ខ្ញុំនៅទីនោះទេ"។ កាលយើងសិក្សាគម្ពីរកិច្ចការជំពូក១៦ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបង្អាក់ដំណើរសាវ័កប៉ុល មិនអោយផ្សព្វផ្សាយដំណឹងល្អនៅក្នុងទ្វីបអាស៊ីទៀតទេ។ ព្រះអង្គតម្រង់សាវ័កប៉ុលអោយធ្វើដំណើរឆ្ពោះទៅទិសខាលិច គឺនាំដំណឹងល្អឆ្ពោះទៅទ្វីបអឺរ៉ុប។ ប៉ុន្តែ ម្តងនេះព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបង្ហាញសាវ័កប៉ុលថា លោកត្រូវដំណើរទៅទីក្រុងយេរូសាឡិម តែព្រះអង្គបើកសម្តែងអោយ

លោកដឹងច្បាស់លាស់ នៅទីនោះលោកត្រូវទទួលរងទុក្ខច្រើន។ ដូច្នេះហើយបានជាលោកបញ្ជាក់ថា "ដឹងតែប៉ុណ្ណេះថា ព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់ដល់ខ្ញុំ នៅគ្រប់ទីក្រុងថា មានចំណងនឹងសេចក្ដីវេទនានៅរង់ចាំខ្ញុំ"។ លោកសុខចិត្តទៅទីនោះ ពីព្រោះលោកចង់បង្ហើយការរត់ប្រណាំងអោយបានចប់ចុងចប់ដើមដោយអំណរ។ ទីក្រុងយេរូសាឡិមជាមូលដ្ឋាន ដែលសាវ័កប៉ុលរាប់ថា សំខាន់សម្រាប់ជីវិតរបស់លោក។ ឥឡូវ សាវ័កប៉ុលព្រមព្រៀងធ្វើដំណើរចុះទៅទីក្រុង យេរូសាឡិមហើយ។

> **២៥ ឥឡូវនេះ មើល ខ្ញុំដឹងហើយថា ក្នុងពួកអ្នករាល់គ្នា ដែលខ្ញុំបាន**
> **ដើរទៅមកជាមួយ ដោយកប់ប្រសព្វគ្នា ទាំងប្រកាសប្រាប់ពីនគរ**
> **នៃព្រះ នោះគ្មានអ្នកណាមួយនឹងឃើញមុខខ្ញុំទៀតឡើយ ២៦ ដូច្នេះ**
> **ខ្ញុំធ្វើបន្ទាល់ដល់អ្នករាល់គ្នានៅថ្ងៃនេះថា ខ្លួនខ្ញុំបរិសុទ្ធពីឈាមអ្នក**
> **រាល់គ្នាទាំងអស់ ២៧ ព្រោះខ្ញុំមិនបានខាននឹងប្រាប់អ្នករាល់គ្នា**
> **ពីគ្រប់ទាំងគំនិតរបស់ព្រះទេ (កិច្ចការ២០:២៥-២៧)។**

សាវ័កប៉ុលយល់ថា លោកមិនអាចត្រឡប់មកជួបមុខពួកជំនុំនៅទីនេះបានទៀតទេ។ ប៉ុន្តែ លោកជ្រាបច្បាស់ហើយថា លោកបានបង្ហាត់បង្រៀនព្រះបន្ទូលទាំងអស់ដល់ពួកមនុស្សដែលលោកបានជួបរួចហើយ។

នៅក្នុងពេលដែលខ្ញុំកំពុងរៀបចំមេរៀនអធិប្បាយនេះ ខ្ញុំមានការពេញចិត្តខ្លាំងណាស់ ដោយសារខ្ញុំអាចបង្ហាត់បង្រៀនព្រះបន្ទូលដល់មនុស្សលោកអោយយល់អំពីច្បាប់របស់ព្រះ។ ក្នុងការអធិប្បាយរបស់ខ្ញុំមានពេលខ្លះក៏អធិប្បាយល្អ មានពេលខ្លះក៏អធិប្បាយធ្វើអោយគេដេកលក់ច្រើនគ្នាដែរ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ខ្ញុំមិនមានការសោកស្តាយទេ ពីព្រោះខ្ញុំជាមនុស្សមានព្រំដែនខាងប្រាជ្ញាយោបល់និងវោហារដែរ។ ប៉ុន្តែ សេចក្តីដែលខ្ញុំពេញចិត្តជាងគេបង្អស់ គឺទីណាដែលខ្ញុំទៅឈរនៅក្រោយអាសនា ដើម្បីប្រកាសដំណឹងល្អពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ខ្ញុំបង្រៀនព្រះបន្ទូលសព្វគ្រប់ដល់មនុស្សលោក។ ខ្ញុំមិនដែលនឹកឃើញថា ខ្ញុំឈរក្រោយអាសនាអធិប្បាយពីសេចក្តីណា ដែលខុសពីព្រះបន្ទូលរបស់ព្រះនោះទេ។

**ដូច្នេះ ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន ហើយនឹងថែរក្សាហ្វូងសិស្ស ដែលព្រះវិញ្ញាណបរិសុទ្ធបានតាំងអ្នករាល់គ្នា ឲ្យធ្វើជាអ្នកគង្វាលដល់គេ ដើម្បីឲ្យបានឃ្វាលពួកជំនុំរបស់ព្រះអម្ចាស់ ដែលទ្រង់បានទិញដោយព្រះលោហិតព្រះអង្គទ្រង់ចុះ (កិច្ចការ២០:២៨)។**

បើលោកអ្នកចង់ដឹងពីតួនាទីរបស់អ្នកចាស់ទុំ និងឥស្សរជនដែលទទួលខុសត្រូវក្នុងក្រុមជំនុំនីមួយៗជាអ្វី ខគម្ពីរខាងលើនេះ បញ្ជាក់ប្រាប់លោកអ្នកស្រាប។ តួនាទីរបស់អ្នកចាស់ទុំ ក្នុងព្រះវិហារនីមួយៗ មិនមែនធ្វើអ្វីក្រៅអំពីការធានារ៉ាប់រងថា វិហារ

របស់អ្នកចាស់ទុំកាន់កាប់នោះ មានការអធិប្បាយព្រះបន្ទូលអោយបានពិតប្រាកដដែរ ឬទេ។

> **[២៩]ដ្បិតខ្ញុំដឹងថា ក្រោយដែលខ្ញុំទៅបាត់ នោះនឹងមានឆ្កែព្រៃដ៏សាហាវ ដែលមិនចេះប្រណីដល់ហ្វូង វានឹងចូលមកក្នុងពួកអ្នករាល់គ្នា [៣០]ហើយក្នុងចំណោមអ្នករាល់គ្នា ក៏នឹងកើតមានមនុស្ស ដែលនឹងអធិប្បាយសេចក្តីទំនាស់ខុសដែរ ដើម្បីនឹងទាញនាំពួកសិស្សទៅតាមគេវិញ (កិច្ចការ២០:២៩-៣០)។**

លោកអ្នកបងប្អូនជាគ្រីស្ទបរិស័ទអើយ រឿងនេះមានកើតឡើងរួចមកហើយ ក៏មានរឿងនេះកំពុងកើតឡើងនៅក្នុងក្រុមជំនុំដែរ។ សាតាំងចង់ជ្រៀតចូលទៅក្នុងក្រុមជំនុំណាដែលមានការបង្ហាត់បង្រៀនព្រះបន្ទូលយ៉ាងត្រឹមត្រូវ។ កិច្ចការដែលខ្ញុំផ្សព្វផ្សាយដំណឹងល្អតាមវិទ្យុនេះ មានអ្នកចង់បំផ្លាញច្រើនណាស់។ អ្នកទាំងនោះចង់បំផ្លាញកិច្ចការដែលខ្ញុំបង្ហាត់បង្រៀនតាមវិទ្យុ ពីព្រោះខ្ញុំបង្ហាត់បង្រៀនព្រះបន្ទូលសព្វគ្រប់របស់ព្រះជាម្ចាស់។ សាតាំងមិនមែនជាមិត្តភក្តិរបស់យើងទេ គឺសត្រូវរបស់យើងវិញ។ សាតាំងមានបំណងតែម្យ៉ាង គឺចង់បញ្ឈប់ការបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះ។ សាវ័កប៉ុលព្រមានដល់ពួកជំនុំនៅទីក្រុងអេភេសូរថា អោយប្រយ័ត្នក្រែងលោសាតាំងនាំអ្នករាល់គ្នាមិនអោយបង្រៀនព្រះបន្ទូលរបស់ទ្រង់។ សាតាំងប្រៀបឧបមា

ដូចជាសត្វខ្មូត ដែលស៊ីឈើសង់ផ្ទះ បណ្តាលអោយផ្ទះទាំងមូលត្រូវរលំទៅបាន។

> **៣១ដូច្នេះ ឱ្យចាំយាមចុះ ចូរនឹកចាំថា ក្នុងរវាង៣ឆ្នាំ ខ្ញុំចេះតែប្រដៅទូន្មានដល់អ្នករាល់គ្នានិមួយៗ ដោយទឹកភ្នែក ទាំងយប់ទាំងថ្ងៃ ឥតឈប់ឈរឡើយ ៣២ឥឡូវនេះ ខ្ញុំផ្ញើអ្នករាល់គ្នាទុកនឹងព្រះ ហើយនឹងព្រះបន្ទូលនៃព្រះគុណទ្រង់ ដែលអាចនឹងស្អាងចិត្ត ហើយនឹងឱ្យអ្នករាល់គ្នាមានកេរ្តិ៍អាករ នៅក្នុងពួកនៃអស់អ្នកដែលបានញែកជាបរិសុទ្ធ (កិច្ចការ២០:៣១-៣២)។**

លុះសាវ័កប៉ុលហៀបនឹងបែកពីគេហើយ លោកបានប្រគល់ពួកជំនុំទៅដល់ព្រះជាម្ចាស់ និងចំពោះព្រះបន្ទូលដែលមានពោរពេញទៅដោយព្រះគុណរបស់ទ្រង់។ នៅពេលណាដែលយើងបែកពីពួកជំនុំទៅទីណា សូមយើងកុំភ្លេចប្រគល់ពួកជំនុំដល់ព្រះជាម្ចាស់ និងដល់ព្រះបន្ទូលនៃព្រះគុណរបស់ទ្រង់ដែរ។

> **៣៣ខ្ញុំមិនដែលលោភចង់បានប្រាក់មាស ឬសំលៀកបំពាក់របស់អ្នកណាឡើយ ៣៤អ្នករាល់គ្នាដឹងហើយថា ដៃខ្ញុំនេះបានផ្គត់ផ្គង់គ្រប់របស់ ដែលខ្ញុំត្រូវការ ព្រមទាំងពួកអ្នកដែលនៅជាមួយផង (កិច្ចការ២០:៣៣-៣៤)។**

សាវ៍កប៉ុល មិនបានមានចិត្តចង់សូមរៃអង្គាសលុយកាក់ពីពួកជំនុំណាទេ។ លោកធ្វើការខ្លួនឯង ដើម្បីឧបត្ថម្ភកិច្ចការងាររបស់ព្រះអង្គផង ឧបត្ថម្ភជីវិតរស់នៅសម្រាប់លោកនឹងគូកនលោកផងដែរ។

> **៣៥ ខ្ញុំបានបង្ហាញអ្នករាល់គ្នាដោយគ្រប់ការទាំងអស់ថា គួរឱ្យខំធ្វើ**
> **ការដូច្នោះ ដើម្បីឱ្យបានជួយដល់ពួកអ្នកខ្សោយ ហើយនឹងនឹកចាំ**
> **ពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ ដែលទ្រង់មានបន្ទូលថា ដែល**
> **ឱ្យ នោះបានពរជាជាងទទួល ៣៦ លុះបាននិយាយសេចក្តីទាំងនោះ**
> **រួចហើយ នោះប៉ុលក៏លុតជង្គង់អធិស្ឋានជាមួយនឹងគេទាំងអស់គ្នា**
> **៣៧ ហើយគ្រប់គ្នាក៏យំជាច្រើន រួចគេឱបកគាត់ថើបដោយថ្នឹតថ្នម**
> **៣៨ ទាំងមានសេចក្តីព្រួយពីពាក្យនេះជាដើម គឺដែលគាត់ថា គេមិន**
> **ឃើញមុខគាត់ទៀតឡើយ រួចក៏ជូនគាត់ទៅដល់សំពៅ (កិច្ចការ**
> **២០:៣៥-៣៨)។**

ការជួបជុំរវាងសាវ័កប៉ុលនិងពួកចាស់ទុំនៃពួកជំនុំទីក្រុងអេភេសូរ មានលក្ខណៈល្អកល្អឺនណាស់។ ពួកអ្នកចាស់ទុំទាំងនោះស្រឡាញ់សាវ័កប៉ុល រីឯសាវ័កប៉ុលក៏ស្រឡាញ់ពួកលោកដែរ។ ពួកអ្នកចាស់ទុំទាំងនោះ មិនចង់អោយសាវ័កប៉ុលត្រឡប់ទៅវិញទេ ប៉ុន្តែលោកទាំងនោះដឹងពិតប្រាកដថា សាវ័កប៉ុលស្គាល់ព្រះហឫទ័យបំណង

របស់ព្រះ បាន ជាលោកលាពួកចាស់ទុំទៅទាំងអាលោះអាល័យ។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"